ការិយាល័យច្រកចេញចូលតែមួយ

សេវារហ័ស

តម្លាភាព

# ONE WINDOW SERVICE OFFICE

## បម្រើប្រជាពលរដ្ឋ ឲ្យកាន់តែប្រសើរឡើង



គាំទ្រដោយ

រាជរដ្ឋាភិបាលកម្ពុជា

ធនាគារពិភពលោក



# ការិយាល័យច្រកចេញចូលតែមួយ

ការិយាល័យច្រកចេញចូលតែមួយគឺជា៖

- កន្លែងផ្តល់សេវារដ្ឋបាលដែលប្រជាពលរដ្ឋត្រូវការចាំបាច់អោយបានទាន់ពេលវេលា មានតម្លាភាព និងតាមនីតិវិធីសាមញ្ញ
- កន្លែងប្រមូលផ្តុំសេវាកម្ម និងនីតិវិធីរដ្ឋបាលមួយចំនួននៅកន្លែងតែមួយ
- កន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ និងទទួលព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ស្តីពីការផ្តល់សេវាសាធារណៈផ្សេងៗ និងការបង់កំរៃសេវាកម្ម
- កន្លែងផ្តល់លទ្ធផលសំរេចជាផ្លូវការលើសេចក្តីស្នើសុំដល់អតិថិជនវិញ។

## តើការិយាល័យច្រកចេញចូលតែមួយមានសេវាកម្មអ្វីខ្លះ?

### ១- វិស័យសាធារណការ និងដឹកជញ្ជូន

- ការចុះបញ្ជីទោចក្រយានយន្ត ត្រីចក្រយាន ត្រីចក្រយានយន្ត
  - ❖ ចេញស្លាកលេខម៉ូតូ
- លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន
  - ❖ ទោចក្រយានសណ្តោងរ៉ឺម៉ក (រ៉ឺម៉កកង់)
  - ❖ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក (រ៉ឺម៉កម៉ូតូ)
  - ❖ ត្រីចក្រយានយន្ត (ម៉ូតូកង់បី)






## ២- វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លិខិតអនុញ្ញាតសាងសង់ ឬជួសជុល

- ភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ មិនលើសពី៥០០ម$^{២}$ និងមិនលើសពីពីរជាន់
- របងដែលមានកំពស់មិនលើស២ម៉ែត្រ

## ៣- វិស័យនីត្យានុកូលកម្ម

បញ្ជាក់លើឯកសារថតចម្លង

- វិញ្ញាបនបត្រប្រកបអាជីវកម្ម
- ប័ណ្ណសំគាល់យានយន្ត
- ព្រឹត្តិបត្រពិន្ទុ វិញ្ញាបនបត្របញ្ជាក់ការសិក្សា
- សៀវភៅស្នាក់នៅ អត្តសញ្ញាណប័ណ្ណ............

## ៤- វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

លិខិតអនុញ្ញាតលើ

- កម្មវិធីសម្តែងផ្សេងៗ ឬបញ្ចាំងភាពយន្តចល័ត
- អាជីវកម្មជួល-លក់ស្នាដៃសិល្បៈភាពយន្តវីដេអូ
- អាជីវកម្មសិល្បៈសូនរូបខ្នាតតូច
- លើកស្លាកសញ្ញាអាជីវកម្ម
- អាជីវកម្មទាក់ទងនឹងគ្រឿងបំពងសម្លេង...........

## ៥- វិស័យឧស្សាហកម្ម រ៉ែ និងថាមពល

ចុះបញ្ជីសិប្បកម្ម និងបន្តវិញ្ញាបនបត្រសិប្បកម្ម ដែលទុនសមមូលសរុបតិចជាង ៥០០០ដុល្លា (ប្រាំពាន់ដុល្លាសហរដ្ឋអាមេរិក)

## ៦- វិស័យទេសចរណ៍

- ផ្ទះភ្ញៀវ (ផ្ទះសំណាក់) មិនលើស០៨បន្ទប់
- ភោជនីយដ្ឋានមិនលើស ៥០នាក់ អាហារដ្ឋាន អាហារដ្ឋានតាមរមណីដ្ឋាន តូបលក់អាហារ ហាងគុយទាវ-កាហ្វេ បំរើភ្ញៀវទេសចរណ៍
- កន្លែងម៉ាស្សាតាមរបៀបបុរាណក្រោម ០៥គ្រែ
- ម៉ូតូឌុបទេសចរណ៍ រ៉ឺម៉កម៉ូតូដឹកទេសចរណ៍ រថយន្តដឹកទេសចរណ៍ចំណុះ ០៥កៅអី............

## ៧- វិស័យពាណិជ្ជកម្ម

លិខិតអនុញ្ញាតប្រកប ឬបន្តអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម

- អាជីវករដែលជាប់កាតព្វកិច្ចបង់ប៉ាតង់ជូនរដ្ឋ
- ការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម

## ៨- វិស័យកសិកម្ម

- វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំលក់រាយសម្ភារកសិកម្ម

## ៩- វិស័យសុខាភិបាល

លិខិតអនុញ្ញាតបើក បន្តសុពលភាព ប្តូរទីតាំង

- បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ
- បន្ទប់ព្យាបាលដោយចលនា
- បន្ទប់ថៃទាំជម្ងឺ
- ឱសថស្ថានរង

# ការផ្ដល់សេវាសាធារណ

ការផ្ដល់សេវានៅការិយាល័យច្រកចេញចូលតែមួយអនុវត្តតាមនីតិវិធីសាមញ្ញ ងាយស្រួល រហ័ស ចំណាយថវិកាតិច និងមានតម្លាភាព។ ការិយាល័យនេះចែកចេញជា២ផ្នែកគឺផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ:** ជាកន្លែងប្រជាពលរដ្ឋមកប្រាស្រ័យទាក់ទងដោយផ្ទាល់ដើម្បីទទួលសេវាពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ផ្នែកជួរមុខមានបីក្រុមៈ

១-**ក្រុមទទួល ប្រគល់ឯកសារ និងផ្ដល់ព័ត៌មាន**ៈ មានភារកិច្ចទទួលពាក្យស្នើសុំ ប្រគល់ឯកសារ និងផ្ដល់ព័ត៌មានជូនប្រជាពលរដ្ឋដោយផ្ទាល់។

២-**ក្រុមនីត្យានុកូលកម្ម**ៈ មានភារកិច្ចធ្វើនីត្យានុកូលកម្មលើឯកសារថតចម្លង។

៣-**ក្រុមបេឡា**ៈ មានភារកិច្ចទទួលកម្រៃសេវាតាមគោលការណ៍កំណត់។







**ផ្នែកជួរក្រោយ:** ជាផ្នែកមានមន្ត្រីជំនាញតាមវិស័យនីមួយៗ ដើម្បីទទួលពិនិត្យពាក្យស្នើសុំ លក្ខណៈបច្ចេកទេស និងលើកយោបល់ជូនអភិបាលក្រុង ស្រុក ខណ្ឌសម្រេច។



## *តើត្រូវស្នើសុំសេវានៅការិយាល័យច្រកចេញចូលតែមួយយ៉ាងដូចម្តេច?*

ប្រជាពលរដ្ឋដែលចង់ស្នើសុំសេវាត្រូវមកទំនាក់ទំនងជាមួយបុគ្គលិកផ្នែកជួរមុខ ដើម្បីទទួលឯកសារទម្រង់បែបបទនៃការស្នើសុំតាមវិស័យនីមួយៗ។

ទម្រង់បែបបទស្នើសុំនេះមានលក្ខណៈសាមញ្ញ ខ្លី និងងាយយល់ សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋដើម្បីបំពេញ។

សម្រាប់ប្រជាពលរដ្ឋដែលមិនចេះអក្សរ និងមិនអាចបំពេញលើទម្រង់បែបបទដោយខ្លួនឯងបាន មន្ត្រីផ្នែកជួរមុខអាចជួយបំពេញជំនួស ដោយសេចក្តីពេញចិត្ត។

មន្ត្រីផ្នែកជួរមុខដែលបានទទួល និងពិនិត្យទម្រង់បែបបទពាក្យស្នើសុំ និងឯកសារភ្ជាប់រួចរាល់ហើយ នឹងចេញបង្កាន់ដៃទទួលពាក្យ ដោយមានកំណត់កាលបរិច្ឆេទដែលអតិថិជនត្រូវមកទទួលអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតលើការស្នើសុំនោះ។

បន្ទាប់មកអតិថិជនត្រូវបង់ថ្លៃសេវាកម្មដោយខ្លួនឯងផ្ទាល់

# លើកកម្ពស់សេវាសាធារណៈ និងអភិបាលកិច្ច





កាលពីមុន ប្រជាពលរដ្ឋចង់ស្នើសុំសេវាកម្មអ្វីមួយ គាត់ត្រូវទ
ទំនាក់ទំនងផ្ទាល់ជាមួយសមត្ថកិច្ចជាច្រើនកន្លែង ចំណាយពេលវេលាយ
និងថវិកាច្រើនប៉ុន្តែពេលនេះ ពួកគាត់គ្រាន់តែមកស្នើសុំសេវាទាំងនេះនៅ
ការិយាល័យច្រកចេញចូលតែមួយជាការស្រេច។

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំសេវ
សាធារណៈដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋនៅនឹងកន្លែងតែមួយប្រកបដោយ
គុណភាព ប្រសិទ្ធិភាព រហ័ស និងតម្លៃសមរម្យ ។ មន្ត្រីបំរើការនៅការិយាល័យ
ច្រកចេញចូលតែមួយបំពេញការងារប្រកបដោយភាពរួសរាយ រាក់ទាក់
និងមានអាកប្បកិរិយាសុភាពរាបសារ និងមិនប្រព្រឹត្តអំពើពុករលួយ។

បច្ចុប្បន្ននេះ ការិយាល័យច្រកចេញចូលតែមួយមានប្រជាពលរដ្ឋ
ពាណិជ្ជករ សិស្ស និស្សិត មកសុំសេវាកម្មកាន់តែច្រើនឡើង ដែលនេះ
បញ្ជាក់ឲ្យឃើញថា ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ
ថ្នាក់ក្រោមជាតិឈានទៅរកភាពវិជ្ជមាន។







## ការិយាល័យប្រជាពលរដ្ឋ

ការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតនៅក្នុងក្រុង ស្រុក ខណ្ឌ គោលដៅនៃការិយាល័យច្រកចេញចូលតែមួយ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អមូលដ្ឋាន និងធ្វើអោយរដ្ឋបាលកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព កាត់បន្ថយអំពើពុករលួយ បង្កើនការចូលរួម ការពេញចិត្ត និងទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងការិយាល័យច្រកចេញចូលតែមួយ។

ការិយាល័យប្រជាពលរដ្ឋដឹកនាំដោយប្រធានមួយរូបហៅថា **ប្រធានការិយាល័យប្រជាពលរដ្ឋ** ។ ប្រធានការិយាល័យប្រជាពលរដ្ឋជាតំណាងអព្យាក្រិតរបស់ប្រជាពលរដ្ឋ ហើយត្រូវបានជ្រើសរើសដោយការបោះឆ្នោត។

## តួនាទី និងភារកិច្ច

ការិយាល័យប្រជាពលរដ្ឋ ជាអង្គភាពធ្វើសកម្មភាពដោយអព្យាក្រិតក្នុងការទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ អំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រុះសម្រួលដោះស្រាយពាក្យបណ្តឹងតវ៉ាទាំងនោះ។ ភារកិច្ចរបស់ការិយាល័យនេះគឺ៖

- ធានាអោយបានថាបញ្ហារបស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយដោយមន្ត្រីរាជការ បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ស្របតាមលក្ខណៈច្បាប់ លិខិតបទដ្ឋាននានាដោយគ្មានបែបបទរដ្ឋបាលច្រើន និងគ្មានការពន្យាពេលលើសពីការកំណត់។

- ការពារប្រជាពលរដ្ឋ និងសហគ្រាសដែលមាននៅក្នុង ក្រុង ស្រុក ខណ្ឌ ប្រឆាំងនឹងការធ្វើសេចក្តីសម្រេចទាំងឡាយណាដែលខុសឆ្គង ដែលបំពានទៅលើច្បាប់ និងលិខិតបទដ្ឋានជាធរមាន។
- ប្រឆាំងនឹងអំពើពុករលួយរបស់មន្ត្រីរាជការ បុគ្គលិករបស់ក្រុង ស្រុក ខណ្ឌ រួមចំណែកដល់ការកសាងទំនាក់ទំនងល្អ និងធ្វើអោយមានទំនុកចិត្តរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌជាមួយប្រជាពលរដ្ឋ។



## ពាក្យបណ្តឹង

ប្រជាពលរដ្ឋអាចធ្វើពាក្យបណ្តឹងទៅការិយាល័យប្រជាពលរដ្ឋក្នុងករណីណាមួយដូចខាងក្រោម៖

- ការសម្រេចចិត្តរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលផ្ទុយនឹងគោលការណ៍ច្បាប់។
- ការអនុវត្តមិនបានសមស្របតាមតួនាទី ភារកិច្ច និងករណីកិច្ចជាអ្នកផ្តល់សេវាដូចជា:
  - ការបដិសេធឬការស្ទាក់ស្ទើរក្នុងការទទួលយកពាក្យស្នើសុំរបស់ប្រជាពលរដ្ឋ ដែលត្រឹមត្រូវតាមច្បាប់។
  - មិនបានផ្តល់លទ្ធផលឬដំណោះស្រាយសមស្របតាមពេលវេលាកំណត់។
  - ការទារលើសកម្រៃសេវាដែលបានកំណត់
  - មានឥរិយាបថមិនអាចទទួលយកបាន ដូចជាការបំភិតបំភ័យឬការប្រមាថមាក់ងាយដល់ប្រជាពលរដ្ឋ ឬតំណាងសហគ្រាសនានា។

# ការគ្រប់គ្រងគម្រោង



- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ជាអ្នកគ្រប់គ្រងគម្រោងរួម។
- អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ជាអ្នកគ្រប់គ្រងគម្រោងដោយផ្ទាល់។
- ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង ដែលបានបង្កើតឡើងដោយ គ.ជ.អ.ប ដើម្បីផ្តល់យោបល់ផ្នែកគោលនយោបាយដល់ការអនុវត្តគម្រោង ដូចជារៀបចំក្របខ័ណ្ឌច្បាប់ គោលនយោបាយ ការបណ្តុះបណ្តាល ត្រួតពិនិត្យ និងវាយតម្លៃ ជួយសម្រួលការរៀបចំរចនាសម្ព័ន្ធ និងការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ រៀបចំសិក្ខាសាលាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូផ្សេងៗទៀត ជាពិសេសការអនុវត្តផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ។
- ក្រុមគាំទ្រក្រុង ស្រុក ខណ្ឌត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ដែលមានសមាសភាពមកពីមន្ត្រីនៃនាយកដ្ឋានពាក់ព័ន្ធនានាចំណុះក្រសួងមហាផ្ទៃ ដើម្បីគ្រប់គ្រង និងគាំទ្រដល់ការអនុវត្តគម្រោងជាប្រចាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.អ.ប នឹងជួយគាំទ្រ និងសម្របសម្រួលនូវសមាសភាគប្រតិបត្តិនៃគម្រោងដូចជា ការអនុវត្តផែនការលទ្ធកម្ម ការគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យា ការផ្ទេរថវិកា សម្របសម្រួលបញ្ហារដ្ឋបាល ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និងការរៀបចំរបាយការណ៍រីកចំរើននៃការអនុវត្តគម្រោង និងកិច្ចការហិរញ្ញវត្ថុទៅលេខាធិការដ្ឋាន គ.ជ.អ.ប

# សាវតារគម្រោង

រាជរដ្ឋាភិបាលកម្ពុជា

ធនាគារពិភពលោក

គម្រោងការិយាល័យច្រកចេញចូលតែមួយ គឺជាសមាសភាគមួយនៃគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន គាំទ្រដោយមូលនិធិពីធនាគារពិភពលោក និងរាជរដ្ឋាភិបាលកម្ពុជា ដែលមានទឹកប្រាក់សរុបជាង ៧.២លានដុល្លារអាមេរិក សម្រាប់រយៈពេល០៤ឆ្នាំចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣។ គម្រោងនេះ មានគោលបំណងសំខាន់ក្នុងការលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ តាមរយៈការពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុកអោយបានទូលំទូលាយ ដោយត្រូវផ្តល់ជូនអតិថិជននូវសេវាកម្មរដ្ឋបាលនៅកន្លែងតែមួយ និងបង្អិតរដ្ឋបាលអោយនៅកៀកជិតនឹងប្រជាពលរដ្ឋ ដើម្បីបង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋអោយបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព សាមញ្ញ តម្លៃថោក ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។




ក្រសួងមហាផ្ទៃ

គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន




## បម្រើសេវារហ័ស តម្លាភាពជូនប្រជាពលរដ្ឋ



**រៀបចំដោយ**

ក្រុមគាំទ្រក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ

អគារ S បន្ទប់ B2, B3 ក្រសួងមហាផ្ទៃ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់

ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ៧២៦ ៨៦១/០២៣ ២២០ ៩៣៥

ទូរសារ: ០២៣ ៧២៦ ៨៦១

Email: info@owso.gov.kh, Website: www.owso.gov.kh